# ការសំភាសន៍របស់ បងស្រី ហៃ ប៊ុន នី

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ ហៃ ប៊ុន នី

<u>ការសង្ខេបប្រវត្តិរបស់ បងស្រី ហៃ ប៊ុន នី</u>

បងស្រី ហៃ ប៊ុន នី មានអាយុ39ឆ្នាំ នៅឆ្នាំ2018 បងស្រី ហៃ ប៊ុន នី មានភេទស្រី បងស្រី ហៃ ប៊ុន នី មានទលំនៅបច្ចុប្បន្ន នៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ជាដំបូងខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិច ដែរមានឈ្មោះថាBYUហាស ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយនឹងប្រវត្តិដូនតាចឹងហាស ហើយពេលដែរខ្ញុំសំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសបង ចឹងសំរាប់បងតើបងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេបង?

ខៈ មានអីបានតើ។

កៈ ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍បងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍បងគឺនៅថ្ងៃទី3ខែ2ឆ្នាំ2018 ហើយការសំភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញហាសបង ចឹងសំរាប់បងឈ្មោះពេញរបស់បងមានឈ្មោះអីគេដែរបង?

ខៈ ខ្ញុំឈ្មោះ ហៃ ប៊ុន នី។

កៈ អូ!ឈ្មោះ ហៃ ប៊ុន នីហោសបង ចឹងសំរាប់បងមានឈ្មោះហៅក្រៅទេបង?

ខៈ នៅក្រៅគេហៅឈ្មោះ នី។

កៈ អូ!ឈ្មោះនីហោស ចុះកាលពីតូចបងមានធ្លាប់ប្រើឈ្មោះអីផ្សេងទៀតទេ?

ខ៖  កាលបីតូចនឹងគេហៅតែឈ្មោះ ញ៉ូវៗនឹង។

ក៖  អូ៎!ឈ្មោះញ៉ូវៗហោសបង ?

ខ៖  ឈ្មោះ ខូវ។

ក៖  អូ៎!ឈ្មោះ ខូវហោសបង ចុះបងសព្វថ្ងៃនឹងបងអាយុប៉ុន្មានដែរបង?

ខ៖  អាយុ39ឆ្នាំ។

ក៖  អាយុ39ឆ្នាំ ចុះថ្ងៃខែរបស់បង បងមានដឹងថាបងកើតនៅថ្ងៃខែឆ្នាំណាដែរទេបង?

ខ៖  អត់ចាំផង ដឹងថាអាយុ39ឆ្នាំ។

ក៖  អាយុ39ឆ្នាំណាបង ចឹងបងកើតនៅឆ្នាំ1979បង
បងកើតនឹងជិតដាប់ពលពតហោសបង?

ខ៖  កាលពីកើតនឹងវាដាច់ហើយនៅមានអាពតមានចូលមួយដែរនឹងហាស។

ក៖  ចឹងមានន័យថាវាចុងដាច់ហើយណាបង?

ខ៖  នឹងហើយខ្ញុំអាពតចូលភូមិនឹងខ្ញុំនៅធំដែរនឹងហាស។

ក៖  អូ៎!បាទបង ចុះបើឆ្នាំខ្មែរហាស លក្ខណៈថាជាឆ្នាំជូត ឆ្លូវ ខាល
ថោះហាសបងឆ្នាំអីគេដែរបង?

ខ៖  ខ្ញុំឆ្នាំមមី។

ក៖  អូ៎!បងឆ្នាំមមីណាបង ចុះបងកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីបងមានចងចាំទេ?

ខ៖  ខ្ញុំនៅខេត្តកំពង់ចាម ស្រុកចំការលើ។

ក៖  នៅស្រុកចំការលើ ចុះភូមិអី ឃុំអីដែរបង?

ខ៖  ភូមិ33 ឃុំចំការអណ្តូង។

ក៖  អូ៎!នៅចំការអណ្តូង នៅជិតស្វាយទាបមែនទេបង?

ខ៖  នឹងហើយ។

ក៖  បាទបង ចុះបងមានបងប្អូនចំនួនប៉ុន្មានដែរបង?

ខ៖  ខ្ញុំមានបងប្អូនចំនួន3នាក់។

ក៖  មានស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរបង?

ខ៖ មានស្រី2នាក់ នឹងប្រុសម្នាក់។

ក៖ ចុះបងជាកូនទីប៉ុន្មានដែរបង?

ខ៖ ខ្ញុំជាកូនទី2 ។

ក៖ ប៉ុន្តែបងអាចប្រាប់បានទេថាបងប្អូនរបស់បងមានឈ្មោះអីគេដែរទេ?

ខ៖ បងប្អូនរបស់ខ្ញុំបងទី1 បងប្រុសឈ្មោះបងមី។

ក៖ ចុះបន្ទាប់មកបង?

ខ៖ នឹងហើយបន្ទាប់មកខ្ញុំនឹងហាស។

ក៖ បន្ទាប់មកទៀតពៅនឹងមានឈ្មោះអីគេដែរបង?
ខ៖ ពៅនឹងឈ្មោះស្រីម៉ាច។

ក៖ ឈ្មោះស្រីម៉ាច ចុះបងមានអនុស្សាវរីយ៍អីជាមួយបងប្អូនរបស់បងទេ?

ខ៖ អនុស្សាវរីយ៍?

ក៖ លក្ខណះថាលេងឡឹកបាយឡ លេងបិទពួន រឺលេងបាញ់ថុយអីចឹងហាស?

ខ៖ កាលនៅពីតូចមិនដែរបានលេងអីជាមួយគ្នាទេនឹងហាស
កាលនៅពីតូចច្រើនតែលក់ដូរ លក់ឥវ៉ាន់ ចឹងលក់បន្លែ មិនសូវបានលេងអីដូចគេផងនឹង។

ក៖ ចឹងមានន័យថាបងនៅជាមួយបងប្អូនរបសបង នឹហបងតែងតែលក់ដូរ
នឹងលក់ឥវ៉ាន់ហោសបង?

ខ៖ នឹងហើយនឹង។

ក៖ ចុះបងចូលចិត្តលេងអីជាមួយបងប្អូនរបស់បងដែរ?

ខ៖ កាលពីនៅតូចនឹងមិនសូវបានលេងអីទេ។

ក៖ អូ៎!ចឹងហោសបង?

ខ៖ ភាគច្រើនចឹងទៅជិះកងឌុបប្អូនទៅរៀនអីចឹងទៅណាស់
មានដួលតាមផ្លូវអីចឹងទៅណា ហើយសើចសប្បាយអីចឹងទៅ ប៉ុន្តែមិនដែរបានលេងទេ។

ក៖ អូ៎!ចឹងបងមិនដែរបានលេងអីទេបង?

ខ៖ នឹងហើយបើលេងអីរវល់ជួយលក់ដូរម៉ែចឹងហាស។

កៈ ចុះបងប្អូនរបស់បងសព្វថ្ងៃនឹងគាត់រស់នៅណាដែរបង?

ខៈ បងខ្ញុំគាត់នៅជិតថៃហោស
ប៉ុន្តែមិនដឹងថានៅណាទេពីព្រោះបានបែកគ្នាអស់ហើយនឹងហាស។

កៈ នឹងបងប្រុសរបស់បងហោស?

ខៈ ចា៎!នឹងហើយ។

កៈ ចុះប្អូនប្រុសនបស់បងគាត់រស់នៅណាដែរបង?

ខៈ នៅចំការលើ។

កៈ ចំការលើហោសបងស្រី?

ខៈ ចា៎!នៅនឹងហាស។

កៈ អូ៎!ចុះបងរបស់បងគាត់ធ្វើអគេដែរបងសព្វថ្ងៃហាស?

ខៈ គាត់នៅជិតថៃនឹងគាត់ទៅធ្វើចំការ ដាំជំឡូងអីដែរនឹង។

កៈ ចុះប្អូនរបស់បងនៅចំការនឹងធ្វើអីដែរបង?

ខៈ ប្អូនរបស់ខ្ញុំនៅចំការលើនឹងដេរខោអាវ កាត់ខោអាវ ចំណែកគ្រួសារគាត់វិញ
ចេះបើកឡាននឹងហាសដឹកចេក ដឹកឥវ៉ាន់គ្រប់មុខចឹងហាស។

កៈ បាទបង ប៉ុន្តែប្អូនរបស់បងគាត់មានគ្រួសារហើយណបង?

ខៈ ចា៎!មានគ្រួសារអស់ហើយនឹងហាស។

កៈ ចុះឪពុករបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ ឪពុករបស់ខ្ញុំគាត់មានឈ្មោះ ប៊ុន ហៃ។

កៈ ចុះគាត់អាយុប៉ុន្មានបងមានចងចាំទេ?

ខៈ ប៉ារបស់ខ្ញុំគាត់ស្លាប់បាត់ហើយនឹង កាលពីគាត់ស្លាប់នឹងគាត់អាយុ50ឆ្នាំជាង
គាត់ស្លាប់យូរដែរហើយជាង30ឆ្នាំហើយនឹងហាស។

កៈ តាំងពី30ឆ្នាំនឹងតាំងពីបងនៅតូចៗមែនបង?

ខៈ ខ្ញុំមានប្ដីហើយនឹងហាស។

កៈ ចឹងបើបងមានប្តីចឹងមានន័យថាមិនទាន់ដល់30ឆ្នាំទេ ពីព្រោះអីបងទើបតែអាយុ39ឆ្នាំនឹងហាសបងមែន?

ខៈ នឹងហើយ។

កៈ ប្រហែលជា20ឆ្នាំជាងតាហីបង?

ខៈ នឹងហើយប្រហែលជា20ឆ្នាំជាងទេ។

កៈ នៅជំនាន់ណា?

ខៈ គាត់ស្លាប់យូរដែរហើយនឹងហាស ប៉ុន្តែខ្ញុំទើបតែបានកូន1នឹងគាត់ក៏ស្លាប់បាត់ទៅណាស់។

កៈ អូ៎!ចឹងហោសបង?

ខៈ ខ្ញុំបានកូនមួយ ហើយខ្ញុំបានពោះធំនៅកូនទី2បានគាត់ស្លាប់បាត់នឹងហាស។

កៈ ចឹងមានន័យថាប្រហែលជាចូលខ្ទង់ចិត ទៅប៉ែតហើយណបង?

ខៈ ចា៎!ប្រហែលប៉ុណ្ណឹង។

កៈ អូ៎!ប៉ុន្តែឪពុករបស់បងគាត់កើតនៅណាបងមានចងចាំទេបង?

ខៈ ប៉ារបស់ខ្ញុំស្រុកកំណើតរបស់គាត់នៅស្ទឹងត្រែងហោស។

កៈ នៅស្ទឹងត្រែងហោសបង?

ខៈ ចា៎!នឹងហើយ។

កៈ ចុះម្តាយរបស់ខ្ញុំកាត់មានឈ្មោះអីគេដែរបង?

ខៈ ចុះម្តាយរបស់បងគាត់មានឈ្មោះជួប រឿន។

កៈ គាត់ឈ្មោះជួប រឿន ចុះគាត់អាយុប៉ុន្មានដែរបងមានចងចាំទេ?

ខៈ ម៉ែរបស់ខ្ញុំគាត់អាយុ60ឆ្នាំជាងហើយ។

កៈ គាត់អាយុ60ឆ្នាំជាង ប៉ុន្តែគាត់នៅរស់ទេណបង?

ខៈ នឹងហើយគាត់នៅរស់តានឹងហាស។

កៈ ចុះគាត់កើតនៅឆ្នាំណាបងមានចងចាំទេបង?

ខៈ អត់ចាំទេ ប៉ុន្តែដឹងតែគាត់ឆ្នាំរកា។

កៈ គាត់ឆ្នាំរកា ប៉ុន្តែបងានដឹងថាគាត់អាយុហុកប៉ុន្មានដែរទេបង?

ខៈ គាត់ប្រហែលជា65-66ឆ្នាំហើយនឹង។

កៈ គាត់អាយុ66ឆ្នាំ ចឹងគាត់កើតនៅឆ្នាំ1952?

ខៈ នឹងហើយគាត់កាលពីអាពតនឹងពិបាកចង់ស្លាប់ហើយគាត់ប្រាប់ខ្ញុំនឹងហាស។

កៈ បាទបង ចុះម្តាយរបស់បងគាត់កើតនៅកំពង់ចាមនឹងតែម្តងហោស?

ខៈ ចា៎!ស្រុកកំណើតរបស់គាត់នៅចំការលើនឹងតែម្តងនឹងហាស។

កៈ នៅចំការលើហោសបង
ចុះឪពុករបស់បងកាលពីគាត់នៅរស់នេងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរបង?

ខៈ គាត់ជាប្រធានមូលដ្ឋានចំការលើ។

កៈ អូ៎!គាត់ជាប្រធានមូលដ្ឋានហោសបង?

ខៈ ចា៎!នឹងហើយ។

កៈ ប៉ុន្តែគាត់ស្លូតរឺមួយក៏កាចដែរបង?

ខៈ គាត់មិនស្លូតទេ ហើយក៏មិនកាចដែរ
ប៉ុន្តែគាត់ទៅធ្វើការងារអីកូនចៅរបស់គាត់គោរពគាត់។

កៈ អូ៎!បាទបង?

ខៈ លក្ខណះកោតខ្លាចចឹងហាស សូម្បីតែកូនចៅក៏ខ្លាច
ហើយនឹងគោរពគាត់ដែរនឹងហាស
បើគាត់និយាយម៉ាត់ណាគឺកូនចៅគោរពតាមគាត់ហើយនឹងហាស។

កៈ ចុះម្តាយរបស់បងគាត់ជាមនុស្សបែបណាដែរបង គាត់ស្លូត រឺមួយក៏កាចដែរបង?

ខៈ ម៉ែរបស់ខ្ញុំគាត់កាចហាស។

កៈ អូ៎!គាត់កាចហោសបង?

ខៈ ម៉ែរបស់ខ្ញុំគាត់កាច។

កៈ ចុះម្តាយរបស់បងគាត់ធ្វើសំរាប់ចិញ្ចឹមជីវិតដែរបង?

ខ៖ កាលពីប៉ារបស់ខ្ញុំគាត់មិនទាន់ស្លាប់នឹងគាត់រកស៊ីរួមរស់ជាមួយប៉ារបស់ខ្ញុំ
ដល់ពេលដែរប៉ារបស់ខ្ញុំគាត់ស្លាប់បាត់ទៅ
គាត់មកភ្នំពេញនឹងលក់លាសជាមួយនឹងខ្ញុំនឹង។

ក៖ ចុះកាលពីបងនៅជាមួយឪពុកម្ដាយរបស់បង
តើបងធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេបង?

ខ៖ ខ្ញុំចងចាំតា កាលពីប៉ារបស់ខ្ញុំមិនទាន់ស្លាប់នឹង គាត់មានប្រពន្ធចុងទៀតចឹង
ប៉ារបស់ខ្ញុំនឹងម៉ែរបស់ខ្ញុំកាត់ស្រលាញ់ខ្ញុំជាងគេម៉ាបងប្អូនទាំងអស់។

ក៖ អូ៎!ចឹងហោសបង?

ខ៖ ពេលដែរប៉ារបស់ខ្ញុំគាត់មានប្រពន្ធចុងចឹង
បងប្អូនៗរបស់ខ្ញុំនឹងគាត់ទៅនៅខាងប៉ារបស់ខ្ញុំទាំងអស់នឹង
ហើយម៉ែរបស់ខ្ញុំគាត់នៅម្នាក់ឯង។

ក៖ អូ៎!ប៉ុន្តែមិនអីទេ?

ខ៖ ដល់ពេលដែរខ្ញុំឃើញម៉ែរបស់ខ្ញុំគាត់នៅម្នាក់ឯងចឹងទៅ ខ្ញុំក៏ចេះតែរត់មកចឹងទៅ
ហើយប៉ារបស់ខ្ញុំគាត់អោយបងរបស់ខ្ញុំបងមីនឹង។

ក៖ ហើយម៉េចទៅបង?

ខ៖ បងខ្ញុំគាត់កំលោះហើយ គាត់ចាប់ខ្ញុំអោយម៉ែខ្ញុំនឹង
ចាប់ពីកន្លែងម៉ែរបស់ខ្ញុំនឹងចាប់ទៅជួបគាត់រហូតចឹងហាស ទៅគាត់ចឹងហាស
ទៅប៉ារបស់ខ្ញុំនឹងអោយបងខ្ញុំចាប់ទៅប៉ារបស់ខ្ញុំរហូតនឹងហាស
ដល់ពេលចាប់ខ្ញុំបានមួយថ្ងៃពីរចឹងទៅក៏រត់មកម៉ែរបស់ខ្ញុំវិញចឹងទៅណាស់។

ក៖ ចឹងបងរត់ទៅមកទៅ?

ខ៖
ចា៎!នឹងហើយខ្ញុំចេះតែអាណិតគាត់ចឹងទៅប៉ារបស់ខ្ញុំគាត់មានប្រពន្ធចុងទៀតនឹងហាស ។

ក៖ បាទបងម៉េចទៀតទៅ?

ខ៖ គាត់មានរហូតដល់គាត់បានស្លាប់ចឹងទៅ។

ក៖ អូ៎!ចឹងហោសបង?

ខ៖  ចា៎!តាំងពីនឹងមកខ្ញុំមិនដែរបានចូលស្រុកចឹងហាស តាំងពីប៉ារបស់ខ្ញុំគាត់ស្លាប់ចឹងមកខ្ញុំចេញពីស្រុករហូតនឹង។

ក៖  ចុះបងចេញពីស្រុកប្រហែលជាប៉ុន្មានឆ្នាំដែរហើយបង?

ខ៖  យូរដែរហើយនឹងហាស តាំងពីប៉ារបស់ខ្ញុំគាត់ស្លាប់មកនឹង។

ក៖  ចឹងមានន័យថាប្រហែលជាជាង30ឆ្នាំហើយណបង?

ខ៖  ចា៎!ខ្ញុំចេញយូរដែរហើយនឹងហាស។

ក៖
ចុះឪពុកម្តាយរបស់បងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងៗទៅបងដែរទេបង ថាឪពុកម្តាយរបស់បងគាត់ធ្លាប់ធ្វើអីគេខ្លះកាលពីនៅក្មេងៗអីចឹងហាស?

ខ៖  ប៉ារបស់ខ្ញុំកាត់មិនដែរប្រាប់ផងនឹងហាស ម៉ែរបសខ្ញុំក៏គាត់មិនដែរប្រាប់អីដែរ។

ក៖  អត់ដែរទេណបង?

ខ៖  គាត់មិនដែរប្រាប់ផងនឹងហាស គាត់ប្រាប់តែកាលពីគាត់នៅអាពតចឹងទៅ កាលបានប៉ារបស់ខ្ញុំចឹងគេបានធ្វើបាបប៉ារបស់ខ្ញុំចឹងទៅ គេធ្វើបាបហើយចឹងទៅម៉ែរបស់ខ្ញុំជួយចឹងទៅណា។

ក៖  អូ៎!ម្តាយរបស់បងគាត់ជួយឪពុករបស់បង?

ខ៖  ចាគាត់ជួយអាពតប្រុងយកប៉ារបស់ខ្ញុំទៅសំលាប់ចឹងទៅ។

ក៖  គេចង់សំលាប់ប៉ារបស់បង?

ខ៖  នឹងហើយគាត់ឃើញប៉ារបស់ខ្ញុំសដូចចិនចឹងហាស គេថាប៉ារបស់ខ្ញុំជាកូនចិន រឺមួយក៏កូនបារាំងចឹងទៅគេថាប៉ារបស់ខ្ញុំគាត់ចេះហាស។

ក៖  បាទបងបាទ?

ខ៖  ថាគាត់ចេះដឹងហាស ដល់ពេលហើយម៉ែរបស់ខ្ញុំគាត់ចេះតែជួយប៉ារបស់ខ្ញុំចឹងទៅ។

ក៖  អូ៎!ឡូយម៉ែរបស់បងជួយប៉ារបស់បង?

ខ៖  ថាអោយគាត់ទៅដាំបាយ អោយគាត់ទៅដាក់បាយជ្រូកអីចឹងទៅណាស់ ជួយនិយាយគេកុំអោយយកប៉ារបស់ខ្ញុំទៅសំលាប់ចោលចឹងទៅណាស់។

ក៖  អូ៎!ពេលណុងម៉េចទៅ?

ខ៖ ពេលណុងគេហៅប៉ារបស់ខ្ញុំគេហៅអោយទៅសរសេរអក្សរអីអោយមើលចឹងទៅ ។

ក៖ គេហៅអយសរសេរអក្សរដែរ?

ខ៖ ហើយម៉ែរបស់ខ្ញុំនឹង
ប្រាប់ប៉ារបស់ខ្ញុំថាពេលដែរហៅអោយសសរសេរអក្សរកុំធ្វើអ្នកចេះអី
ពេលដែរសរសេរអក្សរចេះតែសរសេរៗទៅចឹងហាស។

ក៖ អូ៎!ហើយម៉េចទៅបង?

ខ៖ ខ្លាចគេយកទៅវៃចោល
កាលពីពេលណុងម៉ែរបស់ខ្ញុំគាត់ថាកាលពីពេលដែរអាពតនឹងអ្នកដែរចេះអក្សរគេសំលាប់
ចោលទាល់តែអស់នឹងហាស។

ក៖ បាទបងត្រូវហើយ។

ខ៖ ហើយម៉ែរបស់ខ្ញុំគាត់ប្រាប់ថាកុំអោយធ្វើចេះធ្វើដឹងអីសោះ។

ក៖ ចុះសំរាប់យាយតាខាងឪពុកបងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ខ្ញុំស្គាល់ឈ្មោះយាយរបស់ខ្ញុំ គាត់មានឈ្មោះយាយទូច។

ក៖ ប៉ុន្តែតាអត់ស្គាល់ទេ?

ខ៖ តាអត់ស្គាល់ផង។

ក៖ នឹងខាងឪពុកណាបង?

ខ៖ ចា៎!អត់ស្គាល់ផងនឹងហាស។

ក៖ ចុះបងមានដឹងថាយាយតាខាងឪពុកគាត់កើតនៅណាបងមានដឹងទេ?

ខ៖ ខ្ញុំដឹងតែយាយតារបស់ខ្ញុំគាត់នៅស្ទឹងត្រែងនឹងហាស។

ក៖ អូ៎!គាត់នៅស្ទឹងត្រែងណាបង?

ខ៖ ចា៎!ស្គាល់ប៉ុណ្ណឹង។

ក៖ ចុះយាយតាខាងម្តាយបងស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ យាយខាងម៉ែរបស់ខ្ញុំគាត់មានឈ្មោះយាយលាវ។

ក៖ ចុះតាវិញ?

ខ៖ ហើយតារបស់ខ្ញុំគាត់មានឈ្មោះតាពោ។

ក៖ អូ៎!ឈ្មោះយាយលាវ តាពោ ចុះបងមានដឹងថាគាត់កើតនៅណាដែរទេបង?

ខ៖ គាត់កើតនៅចំការលើនឹងដែរនឹង។

ក៖ អូ៎!បាទបង។

ខ៖ នឹងតារបស់ខ្ញុំ។

ក៖ ប៉ុន្តែបងមានដឹងថាគាត់អាយុប៉ុន្មានឆ្នាំៗបងមានដឹងទេបង?

ខ៖ អត់ស្គាល់ផងនឹង។

ក៖ យាយតាខាងឪពុកនឹងខាងម្ដាយហាស?

ខ៖ នឹងហើយអត់ស្គាល់ផងនឹង។

ក៖ គាត់អាយុប៉ុន្មានៗបងមិនដឹងទេណាបង?

ខ៖ អត់ដឹងទេ។

ក៖ ចុះបងមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅបង?

ខ៖ ខ្ញុំនៅយូរដែរហើយ។

ក៖ ប្រហែលជាប៉ុន្មានឆ្នាំដែរហើយបង?

ខ៖ តាំងពីប៉ារបស់ខ្ញុំស្លាប់បានប៉ុន្មានខែនឹងខ្ញុំមកនៅនឹងរហូតនឹងហាស។

ក៖ ចឹងមានន័យថាបងមកនៅតាំងពីក្មេង?

ខ៖ ខ្ញុំមកនៅភ្នំពេញនឹងតាំងពីខ្ញុំបានកូនមួយមកនឹងហាស។

ក៖ អូ៎!តាំងពីមានកូនហោសបង?

ខ៖ នឹងហើយតាំងពីកូនមួយ កូនពីរមកនៅភ្នំពេញនឹងហាស។

ក៖ បាទបង ចុះបងមានសាច់ញ្ញាតិណាដែររស់នៅក្រៅប្រទេសទេបង?

ខ៖ អត់មានផង។

ក៖ បងប្អូនក៏អត់មានដែរណាបង?

ខ៖ អត់មានទេ។

កៈ ចុះប្តីរបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ ប្តីរបស់ខ្ញុំគាត់មានឈ្មោះអ៊ុំ វិចិត្រ។

កៈ ចុះបងមានចងចាំថ្ងៃដែរបងរៀបអាពាហ៍ពិពាហ៍ទេបង
នៅថ្ងៃខែឆ្នាំណាដែរចឹងហាសបង?

ខៈ ប្តីរបស់ខ្ញុំអត់ចាំដែរនឹងហាស ប្តីខ្ញុំហើយនឹងខ្ញុំនឹងអាយុស្គរគ្នានឹងហាស។

កៈ ប៉ុន្តែកាលពីបងរៀបអាពាហ៍ពិពាហ៍នឹង
ដូចជាបងមានកូនតែម្តងរឺមួយក៏យ៉ាងម៉េចដែរបង?

ខៈ បានមួយឆ្នាំជាងបានមាន។

កៈ មួយឆ្នាំជាងបានមាន ប៉ុន្តែកូនបងបងគេឥឡូវនឹងអាយុប៉ុន្មានដែរបង?

ខៈ បងគេឆ្នាំខាល មិនដឹងអាយុប៉ុន្មានដែរនឹង។

កៈ អូ្!ខ្ញុំអត់ដឹងដែរនឹង?

ខៈ កូនរបស់ខ្ញុំនឹងបីឆ្នាំពីរៗៗនឹង។

កៈ ប៉ុន្តែឥឡូវនឹងអាយុម្ភៃជាងមែនទេបង?

ខៈ ម្ភៃជាងហើយនឹងហាសឆ្នាំខាលហាស គ្រាន់តែកូនរបស់ខ្ញុំមីមួយនេះនឹងអាយុ13-14ឆ្នាំហើយនឹងហាស។

កៈ ចុះបងអាចប្រាប់ថាពេលណាដែរបងស្គាល់ប្តីរបស់បង
ហើយស្គាល់រយះពេលប៉ុន្មានដែរបងស្គាល់គ្នា ហើយហេតុអីបានជាបងស្គាល់គ្នាចឹងហាស
ហើយហេតុអីបានជាប្តីរបស់បងចូលស្តីដណ្តឹងបងចឹងហាសបងអាចប្រាប់បានទេ?

ខៈ អត់ចាំទេ។

កៈ អត់ចាំទេណាបង?

ខៈ អត់ចាំផងនឹងហាស។

កៈ ចុះកាលពីពេលដែរបងរៀបអាពាហ៍ពិពាហ៍នឹងគិតថាបងអ្នករៀបដោយខ្លួនឯង
រឺមួយក៏ឪពុកម្តាយជាអ្នករៀបអោយដែរបង?

ខៈ កាលពីជំនាន់ណុងខ្ញុំគ្មានទេ យើងស្រលាញ់គ្នាចឹងទៅ ក៏ទៅរៀបខាងប្តីរបស់ខ្ញុំចឹងទៅ
ប៉ុន្តែខ្ញុំអត់ចូលស្រុកយូរដែរហើយនឹងហាស។

កៈ អូ៎!បាទបង?

ខៈ ប៉ុន្តែកាលពីពេលណុងមិនដឹងថារៀបថ្ងៃណាអីថ្ងៃណាទេនឹងហាស
ខ្ញុំអត់ានចងចាំទេនឹងហាស។

កៈ អូ៎!បាទ ចុះបងធ្លាប់រៀនទេបង?

ខៈ ខ្ញុំបានរៀនតា កាលពីពេលណុងខ្ញុំបានរៀនបានតិច។

កៈ ចុះកាលពីពេលណុងបងរៀនបានថ្នាក់ទីប៉ុន្មានដែរបង?

ខៈ ខ្ញុំរៀនបានថ្នាក់ទី4នឹងទី5។

កៈ រៀនបានថ្នាក់ទី5ហោសបង?

ខៈ រៀនបានតែប៉ុណ្ណឹង។

កៈ ចុះបងមានចងចាំថារៀននៅណាដែរទេ?

ខៈ ខ្ញុំរៀននៅចំការលើ។

កៈ ប៉ុន្តែបងមានចងចាំថាឈ្មោះបឋមសិក្សាអីទេសាលារបស់បងហាស?

ខៈ អត់ចាំទេចេញយូរដែរហើយនឹងហាស។

កៈ អូ៎!បងអត់ចាំទេ?

ខៈ ចា៎!ឈប់រៀនតាំងពីខ្ញុំនៅតូចមក។

កៈ អូ៎!បាទបង ចុះបងមានចេះភាសាអីក្រៅពីភាសាខ្មែរទេបង?

ខៈ ខ្ញុំចេះតែភាសាខ្មែរនឹង
ភាសាអង់គ្លេសខ្ញុំចេះនិយាយតិចតួចកាលពីមុននឹងខ្ញុំចេះនិយាយច្រើនដែរនឹងហាស។

កៈ អូ៎!ឡូយបងចេះអង់គ្លេស?

ខៈ ភាសាអង់គ្លេសខ្ញុំអាចសន្ទនាគ្នាបាន ប៉ុន្តែអក្សរខ្ញុំអត់ចេះទេ
ប៉ុន្តែខ្ញុំអាចសន្ទនាគ្នាបាននឹងហាស។

កៈ ប៉ុន្តែថៃ វៀតណាមងឺបងចេះទេ?

ខៈ អត់ចេះទេនឹងហាស

កៈ អត់ចេះទេណាបង?

ខ៖ ចា៎!អត់ចេះតេ។

ក៖ ចុះបងធ្លាប់មានមិត្តភក្តិស្និទ្ធស្នាលណាដែរធំធាត់មកជាមួយគ្នាទេ?

ខ៖ អត់មានទេ
កាលពីពេលណុងខ្ញុំមានពួកម៉ាក់មួយប៉ុន្តែពួកម៉ាក់ធំធាត់ជាមួយគ្នាអត់មានទេ។

ក៖ អូ៎!អត់មានទេណាបង?

ខ៖ ប៉ុន្តែគ្រាន់តែថា ខ្ញុំមកនៅភ្នំពេញនឹងខ្ញុំមានពួកម៉ាក់មួយដែរ
ប៉ុន្តែឥឡូវនឹងគេមានប្ដីទៅអូស្រ្តាលីបាត់ហើយនឹងហាស។

ក៖ ចុះគាត់មានឈ្មោះអីគេដែរបង?

ខ៖ ដល់ពេលដែរនិយាយចឹងចង់ភ្លេចឈ្មោះបាត់ ឈ្មោះអាលីន។

ក៖ ឈ្មោះអាលីនហោសបង
ប៉ុន្តែបងមានចងចាំអនុស្សាវរីយ៍អីដែរបងធ្វើជាមួយគាត់ដែរហាសបងមានទេ?

ខ៖ អនុស្សាវរីយ៍មានច្រើនដែរនឹងហាសដើរលេងជាមួយគ្នា
កាលពីពេលណុងខ្ញុំឈ្លោះគ្នាជាមួយប្ដីរបស់ខ្ញុំនឹងពួកម៉ាក់ខ្ញុំអោយខ្ញុំនឹង
ពួកម៉ាក់វាមានសង្សាហាស។

ក៖ បាទបងចឹង?

ខ៖ ដល់ពេលចឹងគាត់ចេះតែណែនាំអោយខ្ញុំនឹងចង់បានជនជាតិគេចឹងហាស។

ក៖ អូ៎!អូយកបរទេសហោសបង?

ខ៖ នឹងហើយពួកម៉ាក់ខ្ញុំប្រាប់ថាអោយខ្ញុំនឹងយកជនជាតិគេទៅណាស់
ឈប់យកប្ដីរបស់ខ្ញុំចឹងទៅណាស់វាពិបាកណាស់ ដល់ពេលចឹងទៅខ្ញុំអត់យកចឹងហាស។

ក៖ អូ៎!បាទបងនឹងហើយ?

ខ៖ ខ្ញុំអត់យកពីព្រោះខ្ញុំចេះតែអាណិតកូនអាណិតប្ដី
ដល់ពេលដែរខ្ញុំអត់យកចឹងទៅក៏បានមកជួបជាមួយប្ដីរបស់ខ្ញុំវិញចឹងហាស។

ក៖ អូ៎!ចឹងបងអត់យកប្ដីបរទេសទេ?

ខ៖
នឹងហើយដល់ពេលដែរពួកម៉ាក់របស់ខ្ញុំអត់ទាន់មានប្តីចឹងទៅក៏ទៅយកតានឹងចឹងទៅក៏បានទៅនៅស្រុកគេចឹងទៅណាស់។

ក៖ អូ៎!ឡូយដែរតា?

ខ៖ រហូតដល់ឥឡូវនឹងហាសកូនមានចៅហើយនឹងហាស។

ក៖ អូ៎!បាទបង ចុះបងធ្លាប់ធ្វើការងារអីគេខ្លះបងតាំងពីក្មេងហាសបង?

ខ៖ អូ៎!នៅពីក្មេងខ្ញុំធ្វើការងារនឿយណាស់។

ក៖ ប៉ុន្តែបងធ្វើអីគេខ្លះដែរទៅ ធ្លាប់ធ្វើការងារអីគេដែរបង?

ខ៖ ធ្លាប់ធ្វើការងារជាជ័រ ។

ក៖ អូ៎!ជាជ័រនៅចំការកៅស៊ូ?

ខ៖ នឹងហើយ។

ក៖ នៅចំការលើយើងនឹងហោសបង?

ខ៖ នឹងហើយនៅចំការលើនឹង ធ្លាប់ធ្វើចំការដាំពោត ដាំសណ្តែកចឹងហាស។

ក៖
ចុះបងគិតថាជីវិតរបស់បងមានការផ្លាស់ប្តូរអីគេខ្លះតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង ពីក្មេងយ៉ាងម៉េច ហើយឥឡូវនឹងយ៉ាងម៉េចដែរចឹងហាស?

ខ៖ ផ្លាស់ប្តូរច្រើនដែរ កាលពីនៅក្មេងធ្លាប់ធ្វើចំការអីចឹងហាស
ដល់ពេលឥឡូវនឹងមកលក់មកអីចឹងហាស ។

ក៖ មួយណាស្រួលជាង?

ខ៖ វាដូចតែគ្នាទេវាមិនសូវបានធ្វើអី ប៉ុន្តែយើងរៀងធូរដែរយើងលក់លាស
ចឹងទៅវាម៉្យាងចឹងហាស ប៉ុន្តែនៅតែហត់នឿយដូចតែគ្នានឹងហាស។

ក៖ អូ៎!ចឹងហោសបង?

ខ៖ វាគ្រាន់តែថាវាមិនដូចយើងធ្វើចំការអីចឹងហាស។

ក៖ បាទបង ចុះម្ហូបអីដែរបងចូលចិត្តពិសារជាងគេដែរបង?

ខ៖ ចូលចិត្តហូបម្ហូបជាងគេគឺសម្លម្ជូរ ទឹកគ្រឿងអីៗចឹងហាស។

កៈ ចុះស្មោរ ការី កកូរ សំឡកអីបងចូលចិត្តដែរបង?

ខៈ ធម្មតាៗនឹងហាស។

កៈ រឺមួយត្រីអាំង រឺខ អីចឹងហាសបងចូលចិត្តទេ?

ខៈ ធម្មតាអានឹង។

កៈ អូ៎!ធម្មតាទេណាបង?

ខៈ ចាំ!ធម្មតាទេ។

កៈ ចុះល្បែងប្រជាប្រិយ៍អីដែរបងចូលចិត្តលេងជាងគេដែរបង ដូចជាចោលឈូង បោះអង្គុញ ទាញព្រាត លាក់កន្សែងអីចឹងហាស កាលពីបងនៅក្មេងៗហាសបង កាលពីបងនៅប៉ុននេះៗអីចឹងហាសបងមានទេ?

ខៈ ចូលចិត្តលេងបោះអង្គុញ។

កៈ ចូលចិត្តលេងបោះអង្គុញហោសបង?

ខៈ ចាំ!សប្បាយ។

កៈ ចុះបងចេះច្រៀងទេ?

ខៈ អត់ចេះច្រៀងទេ។

កៈ បងអត់ចេះច្រៀងទេណាបង?

ខៈ អត់ចេះទេ។

កៈ ប៉ុន្តែបងចូលចិត្តស្តាប់ចំរៀងទេ?

ខៈ ខ្ញុំចូលចិត្តស្តាប់តា។

កៈ ប៉ុន្តែលក្ខណះថាជាបទសម័យ រឺមួយក៏បុរាណដែរបង?

ខៈ ជាបទបុរាណលក្ខណះថាជាបទពីដើមៗនឹងហាស។

កៈ ប៉ុន្តែលក្ខណះថាជាបទអីដែរបងចូលចិត្តស្តាប់ដែរបង លក្ខណះបទមួយដែរបងចូលចិត្តចឹងហាសបងអាចប្រាប់ពីចំណងជើងមួយបានទេ?

ខៈ ខ្ញុំចូលចិត្តស្តាប់ជាងសគេនឹងគឺបទរស់ សារីសុធា បទពោធិនតុង។

កៈ អូ!បទពោចិនតុងហោសបង បអអាចដាក់មួយបានទេ?
ខៈ អត់ចេះផងនឹង។

កៈ និយាយលេងទេបង បងប្រុសមិញគាត់ពូកែច្រៀងប៉ុន្តែបងមិនចេះច្រៀង?

ខៈ ខ្ញុំអត់ចេះច្រៀងទេ។

កៈ ចុះបងគិតថាមានបងប្អូន រឺមានមិត្តភក្តិណាមួយដែរចេះលេងឧបករណ៍ភ្លេងទេបង?

ខៈ អត់មានផងនឹង។

កៈ បងប្អូនជីដូនមួយអីក៏មិនមានដែរ?

ខៈ អត់មានទេ។

កៈ ចុះបងគិតថាផ្ទះរបស់បងមានលក្ខណៈបែបណាដែរ
តាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?

ខៈ ផ្ទះយ៉ាងម៉េចដែរ?

កៈ ថាកាលពីនៅក្មេងនឹងមានផ្ទះលក្ខណៈយ៉ាងម៉េចដែរ ជាលក្ខណៈថាផ្ទះឈើ
រមួយក៏ផ្ទះថ្មចឹងហាសបង?

ខៈ កាលនៅផ្ទះនៅចំការលើមានផ្ទះគេចែកអោយតា ក្រុមហ៊ុនគេចែកអោយ។

កៈ ប៉ុន្តែផ្ទះលក្ខណៈយ៉ាងម៉េចដែរបង?

ខៈ ផ្ទះថ្ម។

កៈ អូ!ផ្ទះថ្មណាបង?

ខៈ ផ្ទះថ្មគេធ្វើជាប់គ្នាៗអោយចឹងហាស។

កៈ អូ!បាទឥឡូវនឹងបង?

ខៈ ឥឡូវនឹងយើងមកយើងជួលផ្ទះគេ។

កៈ ចឹងមានន័យថាផ្ទះនៅណុងដូចជាមានក្រុមហ៊ុន រឺអង្គការគេចែកអោយហើយណបង?

ខៈ ចា៎!គេចែកអោយ។

កៈ ចុះបងគិតថាជំនាញអីដែរបងចេះស្ទាត់ជាងគេដែរបង?

ខៈ ជំនាញ?

កៈ ជំនាញដែរបងគិតថាអាចធ្វើបានហើយចេះស្ទាត់ជំនាញហាស?

ខៈ មានជំនាញអីផងនឹង មានតែលក់លាសនឹងឯង។

កៈ ជំនាញបងលក់លាស?

ខៈ នឹងហើយជំនាញលក់លាស លក់កាហ្វេ លក់ភេសជ្ជៈអីនឹងហាស។

កៈ ចុះម្ដាយឪពុករបស់បងមានធ្លាប់បង្រៀនពីជំនាញអីទៅបងទេ ដូចថាជាលក្ខណៈវេញវល្លិ៍ កូរស្ករ ជាជ័រ លក្ខណៈថាជាត្បាញកន្ទេល ត្បាញក្រម៉ាអីមួយដែរចឹងហាសបង?

ខៈ អត់ចេះផងនឹង។

កៈ អូ៎!បងមិនចេះទេ?

ខៈ ខ្ញុំចេះតែធ្វើនុំក្រូច នុំកង។

កៈ អូ៎!បងចេះធ្វើនុំក្រូចហោស?

ខៈ នឹងហើយចេះធ្វើតែនុំក្រូច នុំកង លក់ភេសជ្ជៈអីនឹងហាស កាហ្វេអីនឹងខ្ញុំចេះឆុង។

កៈ ចុះបងឯងអាចប្រាប់ថាពេលណាដែរបងគិតថា ជាពេលដែរលំបាកនៅក្នុងជីវិតរបស់បងបានទេបង?

ខៈ អូយខ្ញុំពិបាកឆ្អែតហើយតាំងពីតូចរហូតមកដល់ពេលនឹង។

កៈ ពិបាកអីគេខ្លះដែរ?

ខៈ និយាយរៀបរាបឆ្អែតតែម្ដងនឹងហាស និយាយទៅវេទនាពិបាកណាស់។

កៈ ចុះបងអាចនិយាយនូវអ្វីដែរបងអាចប្រាប់បានខ្លះៗដែរបានទេ?

ខៈ កាលខ្ញុំនៅពីតូចនឹងខ្ញុំពិបាកម៉ែឪរបស់ខ្ញុំគាត់មានប្រពន្ធចុង គាត់មិនដែរសូវមានពេលជួបជុំគ្នាអីចឹងហាស ខ្ញុំអាណិតម៉ែរបស់ខ្ញុំនឹង ខ្ញុំពិបាក។

កៈ បាទបងមានអីទៀត?

ខៈ ធ្វើការជាជ័រ ជាកៅស៊ូ ជាអីចឹងទៅណាស់។

កៈ អូ៎!បងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរបង?

ខ៖  ពិបាកហាសណាមួយទៅ ខ្ញុំអាណិតម៉ែរបស់ខ្ញុំចឹងទៅ ពេលដែរទៅជួយធ្វើការងារគាត់ជួយជាជ័រ ជាកៅស៊ូ អីចឹងទៅ នឹងធ្វើចំការអីចឹងទៅណាស់ ខ្ញុំនឹកឃើញគាត់មេម៉ាអីចឹងផងនឹងហាស។

ក៖  អូ៎!បាទបងត្រូវហើយ។

ខ៖  ដល់ពេលដែរខ្ញុំមកភ្នំពេញចឹងទៅវារៀងធូរធ្វើការងារចឹងដែរនឹងហាស រកស៊ីអីដូចថាយើងម្ចាស់ការខ្លួនឯងចឹងទៅ ។

ក៖  បាទវាស្រួលជាងធ្វើការងារអោយគេណាបង?

ខ៖  ចា៎!វាស្រួលត្រង់ថាពេលដែរយើងចង់រកក៏រកទៅ ចង់ដេកផ្ទះក៏ដេកទៅចឹងហាស។

ក៖  បាទបងត្រូវ។

ខ៖  គ្មាននរណាគេមកថាអោយយើងចឹងហាស។

ក៖  ចុះបងគិតថាពេលណាដែរបង គិតថាជាពេលដែរបងសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់បងដែរចឹងហាសបង?

ខ៖  សប្បាយជាងគេ?

ក៖  ដូចជាលក្ខណះថាពេលដែរបងរៀបអាពាហ៍ពិពាហ៍ខ្លួនឯង រឺមួយក៏រៀប។អាពាហ៍ពិពាហ៍អោយកូនចៅ ដែរធ្វើអោយបងសប្បាយជាងគេដែរចឹងហាស?
ខ៖  ដូចថាពេលដែរគ្រួសារសប្បាយចិត្តជួបជុំគ្នា យើងនៅថ្ងៃបុណ្យ ខែទានចឹងហាសយើងជួបជុំគ្នាចឹងទៅយើងសប្បាយ។

ក៖  នឹងធ្វើអោយបងសប្បាយជាងគេហើយណាបង?

ខ៖  ចា៎!នឹងហើយ។

ក៖  ចុះបងធ្លាប់មានក្តីស្រម៉ៃដែរទេថាកាលពីនៅក្មេងៗហាស បងធ្លាប់ស្រម៉ៃថាពេលដែរធំឡើងបងចង់ធ្វើអីគេដែរ?

ខ៖  ខ្ញុំធ្លាប់ស្រម៉ៃដែរតា ថាកាលនៅពីតូចនឹងចង់អោយម៉ែឪរបស់ខ្ញុំនឹងនៅជួបជុំគ្នាចឹងទៅ កុំអោយបែកបាក់គ្នាចឹងទៅណាស់ប៉ុន្តែវាមិនអាចទេ។

ក៖  អូ៎!ចឹងម៉េចទៅបង?

ខ៖  នៅតែបែកបាក់គ្នាចឹងទៅណាស់។

កៈ ចុះកាលពីបងនៅរៀនបងធ្លាប់មានក្តីស្រម៉ៃថា
ពេលដែរបងធំឡើងបងចង់ធ្វើជាគ្រូបង្រៀន គ្រូពេទ្យ រឺក៏ប៉ូលីសអីដែរទេបង?

ខៈ ចង់ស្រម៉ៃអីបើគេចសាលារហូតនឹង។

កៈ អូ៎!បងគេចសាលារហូត?

ខៈ ខ្ញុំគេចសាលារហូតនឹងមិនដែរបានចូលរៀនផងនឹងហាស។

កៈ បងប្រាប់អោយមីអូនលីនឹងមីអូនគេចដែរត្រូវហើយ?

ខៈ គ្មានទេមិនអោយធ្វើទេ។

កៈ ខ្ញុំនិយាយលេងទេ?

ខៈ អត់អីទេ។

កៈ ចុះបើចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗបងចង់ផ្តែផ្តាំអីពួកគាត់ដែរបង
អោយគាត់ខំប្រឹងរៀន ដើម្បីអោយមានការងារល្អចឹងហាសបង?

ខៈ ចាំ!ចង់ផ្តែផ្តាំថា ចឹងបានផ្តែផ្តាំអោយកូនខំប្រឹងរៀននឹងហាស
កុំអោយវាល្ងង់ដូចខ្ញុំចឹងហាស។

កៈ បាទចឹងហោសបង?

ខៈ ចង់អោយវាខំប្រឹងរៀនចឹងទៅគ្រាន់វាបានធ្វើការងារល្អអីចឹងហាស។

កៈ បាទបងមានអីទៀតទេ?

ខៈ អត់ចង់អោយវាខ្វិលនឹងការងារ នឹងខ្វិលរៀននឹងទេ
នឹងកុំអោយទាក់ទងគ្រឿងញៀនអីកុំអោយដូចខ្ញុំនឹងហាស
ពីព្រោះថាសម័យឥឡូវនឹងគេត្រូវការតែអ្នកចេះទេ
បើអ្នកដែរល្ងង់នឹងចង់ទៅធ្វើការងារនៅណាក៏គេមិនទទួលដែរ។

កៈ បាទត្រូវហើយបង។

ខៈ នឹងហើយ។

កៈ ចុះបងមានអីចង់ផ្តែផ្តាំផ្សេងទៀតទេបង?

ខៈ អត់មានទេ។

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់បង
បាទអរគុណច្រើនហាសបង៕៕៕